មើលវីដេអូ ភាគទី ១៥

* ហិរិ មានការគោរពខ្លួន ទើបមិនធ្វើបាប ដោយខ្មាស ដូចស្រីក្រមុំមានត្រកូលល្អរង្កៀស (ខ្ពើម) វត្ថុបដិកូលចំណែក

* ឱត្តប្បៈ មានការគោរពអ្នកដទៃ ទើបមិនហ៊ានធ្វើបាប ព្រោះការក្រែងខ្លាច ដូចស្រីពេស្យា មានការក្រែងខ្លាចអ្នកដទៃ។

* ហិរិ និង ឱត្តប្បៈ នេះ លោកហៅថា លោកបាលធម៌ (ធម៌តែងរក្សានូវសត្វលោក) ជាធម៌យ៉ាងស្ងប់ មិនរាយមាយ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# ៥ - អលោភចេតសិក (Non-attachment)

លោភបដិបក្ខោ = អលោភោ ធម៌ដែលបដិបក្ខនឹងលោភៈ ឈ្មោះថា អលោភៈ។

*ម្យ៉ាងទៀត* ន លុព្ភន្តិ តេន សយំ វា ន លុព្ភតិ អលុព្ភនមត្តមេវ វា តន្តិ = អលោភោ សត្វទាំងឡាយ មិនលោភដោយធម៌នោះ ហេតុនោះ ធម៌នោះ ឈ្មោះថា អលោភៈ ឬធម៌ណា ខ្លួនឯងមិនលោភ ធម៌នោះ ក៏ឈ្មោះថា អលោភៈ ឬថា ធម៌នោះ ត្រឹមតែមិនលោភប៉ុណ្ណោះ ក៏ឈ្មោះថា អលោភៈ។

# លក្ខណាទិចតុក្កៈរបស់អលោភៈ

១ - អលគ្គភាវលក្ខណោ មានការមិនជាប់ជំពាក់នឹងអារម្មណ៍ ជាលក្ខណៈ

*ដូចដំណក់ទឹក មិនជាប់នឹងស្លឹកឈូក*

២ - អបរិគ្គហរសោ មានការមិនហួងហែង ជាកិច្ច

៣ - អនល្លីនភាវបច្ចុប្បដ្ឋានោ មានការមិនប្រកាន់មាំក្នុងអារម្មណ៍ ជាអាការប្រាកដ

*ដូចអ្នកធ្លាក់ទៅក្នុងរណ្ដៅលាមក*

៤ - យោនិសោមនសិការបទដ្ឋានោ មានយោនិសោមនសិការៈ ជាហេតុជិត។

# ៦ - អទោសចេតសិក (Goodwill)

ទោសបដិបក្ខោ = អទោសោ ធម៌ដែលបដិបក្ខនឹងទោសៈ ឈ្មោះថា អទោសៈ។ សេចក្ដីក្រៅពីនេះ មានការវិនិច្ឆ័យ ស្រដៀង នឹង អលោភៈ។ មេត្តា ក្នុងព្រហ្មវិហារធម៌ អង្គធម៌គឺ អទោសៈ ហ្នឹងឯង។

# លក្ខណាទិចតុក្កៈរបស់អទោសៈ

១ - អចណ្ឋិក្កលក្ខណោ — មានការមិនកាច ជាលក្ខណៈ *ដូចមិត្តអ្នកអនុគ្រោះប្រយោជន៍*

២ - អាឃាតវិនយរសោ — មានការកំចាត់អាឃាត (ឬមានការមិនចងគំនុំ) ជាកិច្ច

៣ - សោមភាវបច្ចុប្បដ្ឋានោ — មានសេចក្តីត្រជាក់ ជាអាការប្រាកដ *ដូចព្រះចន្ទពេញវង់*

៤ - យោនិសោមនសិការបទដ្ឋានោ — មានយោនិសោមនសិការ ជាហេតុជិត។

## ៧ - តត្រមជ្ឈត្តតាចេតសិក (Equanimity)

តេសុ តេសុ ធម្មេសុ មជ្ឈត្តតា = តត្រមជ្ឈត្តតា

ភាពជាកណ្តាលក្នុងធម៌នោះៗ ឈ្មោះថា តត្រមជ្ឈត្តតា។

# លក្ខណាទិចតុក្កៈរបស់តត្រមជ្ឈត្តតា

១ - ចិត្តចេតសិកានំ សមវាហិតលក្ខណា — មានការនាំចិត្តនិងចេតសិកទៅដោយស្មើជានិច្ច (ឬមានការទ្រទ្រង់ចិត្តនិងចេតសិកឲ្យស្មើ) ជាលក្ខណៈ

២ - ឩនាធិកតានិវារណរសា — មានការហាមនូវភាពលើសខ្វះគ្នាជាកិច្ច

៣ - មជ្ឈត្តភាវបច្ចុប្បដ្ឋានា — មានភាពជាកណ្ដាល ជាអាការប្រាកដ

៤ - សម្បយុត្តបទដ្ឋានា — មានសម្បយុត្តធម៌ ជាហេតុជិត ។

តត្រមជ្ឈត្តតាចេតសិក នេះ មានន័យច្រើន បណ្ឌិត គប្បីឃើញដោយភាពព្រងើយនៃចិត្ត និងចេតសិកទាំងឡាយ ដូចសារថី សម្លឹងមើលព្រងើយៗ នូវសេះអាជានេយ្យដែលរត់ទៅស្មើល្អហើយ ដូច្នោះ។